**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៣៣៣៣*៤៤៤៤

**រាជរដ្ឋាភិបាល**

**ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

**គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា**

# សេចក្តីប្រកាសព័ត៌មាន

នាព្រឹកថ្ងៃទី ១៨ ខែ តុលា ឆ្នាំ២០១០ វេលាម៉ោង ០៨ : ៣០ នាទី នៅវិមានរដ្ឋាភិបាល (*ទីស្តីការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*) គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា បានរៀបចំកិច្ចប្រជុំលើកទី១៧ នៃគណៈកម្មាធិការសម្របសម្រួល រវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ (Government-Donor Coordination Committee-GDCC) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី គាត ឈន់** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអនុប្រធានទី១ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងអមដោយ **ឯកឧត្តម ឈឿន យ៉ាណារ៉ា** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាអគ្គលេខាធិការ គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា (គ.ជ.ទា/ក.អ.ក) ។ កិច្ចប្រជុំនេះក៏មានការអញ្ជើញចូលរួមពីសំណាក់ ឯកឧត្តម លោកជំទាវ ជាប្រធានស្ថាប័នរបស់រាជរដ្ឋាភិបាល ប្រធានក្រុមការងារបច្ចេកទេសចម្រុះ និងលេខាធិការដ្ឋានរបស់ក្រុមការងារ ។ រីឯភាគីដៃគូអភិវឌ្ឍន៍រួមមាន ឯកឧត្តម លោកជំទាវ ជាឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត និងប្រធានស្ថានតំណាងដៃគូអភិវឌ្ឍន៍ ទ្វេភាគី ពហុភាគី ព្រមទាំងតំណាងសង្គមស៊ីវិលផងដែរ។

កិច្ចប្រជុំលើកនេះមានគោលបំណងសំខាន់ដើម្បីពិនិត្យមើលវឌ្ឍនភាពសំខាន់ៗ ដែលវិស័យនិមួយៗសម្រេចបានក្រោយពីការឯកភាពគ្នារវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នៅក្នុងវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣នាថ្ងៃទី ២-៣ ខែ មិថុនា ឆ្នាំ២០១០ កន្លងមក។ កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ លើកទី១៧នេះ មានរបៀបវារៈលម្អិតចំនួនពីរគឺ៖

*១-វឌ្ឍនៈភាពក្នុងការអនុវត្តន៍សកម្មភាពនិងសូចនាករតាមដានរួមគ្នា ដែលបានឯកភាពគ្នាក្នុងវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣ នាខែ មិថុនា ឆ្នាំ២០១០ ព្រមទាំងសូចនាករសំខាន់ៗដែលនឹងត្រូវលើកមកពិភាក្សាលើកនេះ មានដូចជា៖*

ក-ការអនុម័តលើសេចក្តីព្រាងខ្លឹមសារកែសម្រួលឯកសារណែនាំស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមការងារបច្ចេកទេសចម្រុះ និងឯកសារទស្សនាទានស្តីពីអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ដែលឯកសារទាំងពីរនេះត្រូវបានរៀបចំឡើងដោយ គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា និងបានផ្ញើជូន

ក្រុមការងារ ព្រមទាំងបានធ្វើការពិភាក្សានៅកម្រិតបច្ចេកទេសរួចរាល់ហើយ។ ឯកសារទាំងពីរនេះនឹងក្លាយជាឯកសារស្នូល ក៏ដូចជាផែនទីចង្អុលផ្លូវសម្រាប់ក្រុមការងារបច្ចេកទេសចម្រុះ និងវិស័យដើម្បីពង្រឹងភាពជាម្ចាស់ និងដឹកនាំកិច្ចអភិវឌ្ឍន៍ក្នុងទិសដៅដើម្បីសម្រេចអោយបាននូវគោលដៅអភិវឌ្ឍន៍។

ខ- វឌ្ឍនភាពនៃក្របខ័ណ្ឌតាមដាននិងវាយតម្លៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៩—២០១៣

គ- វឌ្ឍនភាពនៃការអនុវត្តន៍ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ អំពីការរៀបចំស្ថាប័ន និងតម្រូវការធនធានសម្រាប់អនុវត្តច្បាប់ស្តីពីការប្រឆាំងអំពើរពុករលួយ ។

ឃ-វឌ្ឍនភាពនៃការរៀបចំយុទ្ធសាស្ត្រជាតិគាំពារសង្គម

ង-កិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ក្នុងការរៀបចំបញ្ចប់ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់តុលាការ និងច្បាប់ស្តីពីលក្ខន្តិកៈនៃអង្គចៅក្រម និងព្រះរាជអាជ្ញា។

២-*ការធ្វើបច្ចុប្បន្នភាព ស្តីពីវឌ្ឍនភាពកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលដែលត្រូវផ្តោតការយកចិត្តទុកដាក់លើកិច្ចប្រឹងប្រែងរយៈពេលវែង ដើម្បីធានាឱ្យមានរដ្ឋបាលសាធារណៈមួយដែលមានសមត្ថភាពរឹងមាំផ្អែកលើគោលការណ៍សមធម៌ ឯកភាព ចីរភាព ស្មារតី តម្លាភាពនិងសមត្ថភាពការងារ។*

គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (ក.អ.ក/គ.ជ.ន) ក្នុងឋានៈជាលេខាធិការដ្ឋាននៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ នឹងបានរៀបចំរបាយការណ៍សង្ខេបលទ្ធផលនៃកិច្ចប្រជុំនេះជូន **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ដើម្បីផ្តល់អនុសាសន៍ជាយថាហេតុ ។

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០